# ព្រះរាជក្រម

នស/រកម/១២១៧/០៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើធម្មនុញ្ញ
# នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

**មាត្រា ១.-**

អនុម័តយល់ព្រមលើធម្មនុញ្ញនៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ដែលត្រូវបានចុះហត្ថលេខា នៅរាជធានីបាងកកនៃព្រះរាជាណាចក្រថៃ នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ហើយដែល មានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តកល់នីតិវិធីដើម្បីអនុវត្តធម្មនុញ្ញនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ថ្ងៃ សៅរ៍ ៦រោច ខែ មិគសិរ ឆ្នាំរកា ព.ស. ២៥៦១
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ ធ្នូ គ.ស. ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពស. ១០៧២. ១១៨៩៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជា**
**អនុប្រធានប្រចាំការនៃគណៈកម្មាធិការជាតិ**
**គ្រប់គ្រងគ្រោះមហន្តរាយ**
**ហត្ថលេខា**
**ញឹម វណ្ណដា**

**លេខ:១១៨១ ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ០៩រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
ច/២
**សយ សុខា**

**KINGDOM OF CAMBODIA**

**NATION - RELIGION - KING**

Ministry of Foreign Affairs
and International Cooperation

*Deputy Prime Minister*

# FULL POWER

I, **HOR Namhong**, Deputy Prime Minister, Minister of Foreign Affairs and International Cooperation of the Kingdom of Cambodia, do hereby certify that the Royal Government of Cambodia has given full power and authority to

**His Excellency Mr. UNG Sean**
Ambassador Extraordinary and Plenipotentiary of the
Kingdom of Cambodia to Thailand

to sign, on behalf of the Royal Government of Cambodia, the new **CHARTER OF ASIAN DISASTER PREPAREDNESS CENTER.**

IN WITNESS WHEREOF this Full Power is signed and sealed at Phnom Penh, on this 25 day of February 2005.

***HOR NAMHONG***

Address : N° 161. Preah Sisowath Quay.
Phnom Penh. Kingdom of Cambodia

Tel : (855) 23 214 441 . 216 122
Fax : (855) 23 216 144 . 216 939
Email: [illegible]

adpc

# ធម្មនុញ្ញ
# នៃ
# មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

# ធម្មនុញ្ញ
# នៃ
# មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

## មាត្រា ១
## ការបង្កើត និងការប្រព្រឹត្តទៅ

១.១ ផ្អែកតាមធម្មនុញ្ញនេះ ស្ថាបនិកទាំងឡាយបានបង្កើតមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ដែលហៅកាត់ថា **អេឌីភីស៊ី** ។ **អេឌីភីស៊ី** ធ្វើប្រតិបត្តិការក្នុងនាមជាអង្គការថ្នាក់តំបន់និងអន្តរជាតិ ស្វយត និងមិនស្វែងរកប្រាក់ចំណេញ ហើយមិនមាននិន្នាការនយោបាយក្នុងការគ្រប់គ្រង ទាំងបុគ្គលិក និងការប្រតិបត្តិ។ **អេឌីភីស៊ី** ត្រូវបានរៀបចំឡើងក្នុងគោលបំណងមនុស្សធម៌ អភិវឌ្ឍន៍ អប់រំ និងវិទ្យាសាស្ត្រ ។

១.២ ទីស្នាក់ការកណ្តាលរបស់ **អេឌីភីស៊ី** ស្ថិតនៅក្នុងប្រទេសថៃ។

១.៣ ភាសាអង់គ្លេសជាភាសាផ្លូវការ ត្រូវបានប្រើសម្រាប់ធ្វើការទំនាក់ទំនង និងកិច្ចការងារទូទៅរបស់ **អេឌីភីស៊ី**។ ទោះយ៉ាងនេះក្តី ភាសាទាំងអស់ដែលមានការពាក់ព័ន្ធទៅនឹងប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ត្រូវបានយកមកប្រើ តាមជាក់ស្តែង ក្នុងគោលបំណងបណ្តុះបណ្តាលលើផ្នែកបច្ចេកទេស ការណែនាំ និងការផ្សព្វផ្សាយព័ត៌មានដល់សិក្ខាកាម ឬសាធារណជន។

## មាត្រា ២
## សមាជិកភាព

២.១ សមាជិកភាពរបស់**អេឌីភីស៊ី** ត្រូវបានបើកចំហចំពោះរដ្ឋសមាជិកដទៃទៀតរបស់អង្គការសហប្រជាជាតិ។

២.២ ហត្ថលេខីនៃធម្មនុញ្ញនេះ គឺជាសមាជិកស្ថាបនិករបស់ **អេឌីភីស៊ី**។

២.៣ សមាជិកទាំងឡាយនឹងមិនតម្រូវឱ្យបង់ថ្លៃសមាជិកភាពរបស់ខ្លួនឡើយ ក៏ប៉ុន្តែអាចចូលរួមវិភាគទានដោយស្ម័គ្រចិត្តដល់មូលនិធិរបស់ **អេឌីភីស៊ី**។

## មាត្រា ៣
## ចក្ខុវិស័យ និងគោលដៅ

៣.១ ចក្ខុវិស័យរបស់ **អេឌីភីស៊ី** គឺ ចង់បានសហគមន៍កាន់តែមានសុវត្ថិភាព និងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពតាមរយៈការកាត់បន្ថយគ្រោះមហន្តរាយ។

៣.២ **អេឌីភីស៊ី** មានគោលដៅ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ ក្នុងសហគមន៍និងបណ្តាប្រទេសក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ មជ្ឈមណ្ឌលនឹងបន្តប្រកាន់យកនូវគោលដៅ

របស់ខ្លួន សម្រាប់បម្រើផលប្រយោជន៍សង្គមដ៏ធំសម្បើម ជាមួយនឹងទស្សនវិស័យ វប្បធម៌ ចម្រុះតាមមធ្យោបាយដូចខាងក្រោម៖

(ក) ជួយដល់បណ្តាប្រទេសនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក និងសហគមន៍ទាំងឡាយ ក្នុងការអភិវឌ្ឍគោលនយោបាយ និងសមត្ថភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ ដោយគ្រោះមហន្តរាយ តាមរយៈការរៀបចំ ការផ្តល់ជូន ការសម្របសម្រួល ដោយការគាំទ្រកម្មវិធីបណ្តុះបណ្តាល ការគ្រប់គ្រងព័ត៌មាន ការស្រាវជ្រាវ ការគ្រប់គ្រងគម្រោង ឬកម្មវិធី ព្រមទាំងជំនួយបច្ចេកទេស។

(ខ) ជួយលើកកម្ពស់ ការយល់ដឹងអំពីគ្រោះមហន្តរាយ ដើម្បីការពារអាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន។

(គ) ជួយលើកកម្ពស់បណ្តាញការងារ និងកិច្ចសហការរវាងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ តំបន់ និងថ្នាក់ជាតិ។

(ឃ) ជួយលើកកម្ពស់ ការផ្លាស់ប្តូរនូវបទពិសោធន៍ និងមេរៀនទទួលបាន ក្នុងគ្រោះមហន្តរាយរវាងបណ្តាប្រទេស សហគមន៍ និងអង្គការនានា។

(ង) សហការលើគ្រប់វិស័យដែលពាក់ព័ន្ធទាំងអស់ ដើម្បីពង្រឹងសមត្ថភាពក្នុងសហគមន៍ ក្នុងការចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ ការត្រៀមបង្ការគ្រោះមហន្តរាយ។

(ច) លើកកម្ពស់ និង អនុវត្តជាលក្ខណៈបុគ្គល ឬជាដៃគូរជាមួយនឹងអង្គការជាតិ និងអន្តរជាតិដទៃទៀត ឬកម្មវិធី និងសកម្មភាព បម្រើផលប្រយោជន៍សាធារណៈ។

(ឆ) តាមការដែលអាចអនុវត្តបាន ខិតខំដាក់បញ្ចូលនូវចំណេះដឹងបែបទំនើប រួមទាំងដំណើរការងារជាស្ថាប័ន ទៅក្នុងផ្នត់គំនិត និងទំនៀមទម្លាប់ដែលមានពីមុន មកនៅក្នុងសហគមន៍ ដើម្បីឆ្ពោះទៅរកការសម្រេចនូវគោលដៅ។

(ជ) ធ្វើជាស្ពានរវាងរដ្ឋាភិបាល អង្គការនានា ស្ថាប័នសង្គមស៊ីវិល ដូចជាសហគមន៍នៅក្នុងតំបន់ និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត។

(ឈ) ធ្វើជាវេទិកាសម្រាប់ការអភិវឌ្ឍ ការពង្រឹងសហប្រតិបត្តិការក្នុងចំណោមបុគ្គល និងអង្គការនានាដូចជារដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន សហគមន៍ក្នុងតំបន់ក៏ដូចជា ថ្នាក់ដឹកនាំរបស់ពួកគេ អ្នកកាសែត អ្នកស្រាវជ្រាវ អ្នកធ្វើផែនការ អ្នកធ្វើគោលនយោបាយ និងអ្នកអនុវត្តនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ដែលការងាររបស់ពួកគេស្របគ្នា នឹងគោលបំណងរបស់ **អេឌីភីស៊ី** ។

(ញ) សម្រេចបាននូវនិរន្តរភាពផ្នែកថវិការយៈពេលវែង។

៣.៣ ដើម្បីគាំទ្រដល់គោលដៅរបស់ខ្លួន **អេឌីភីស៊ី** ត្រូវចាត់ចែង និងសម្របសម្រួលការងារទាក់ទងនឹងការស្រាវជ្រាវ ជំនួយបច្ចេកទេស ការផ្លាស់ប្តូរព័ត៌មាន សិក្ខាសាលា សន្និសីទ សកម្មភាពបណ្តុះបណ្តាលផ្សេងៗ ជាមួយនឹងបុគ្គល និងស្ថាប័ន ការគៀគររកមូលនិធិ សម្រាប់លើកកម្ពស់នូវសេវាកម្មរបស់ខ្លួន និងសកម្មភាពដទៃទៀត ដែលកើតចេញពី ឬ

បង្កើនតួនាទីរបស់ **អេឌីភីស៊ី** ដែលជាមជ្ឈមណ្ឌលតំបន់មួយ សម្រាប់ការលើកកម្ពស់ការកាត់បន្ថយគ្រោះមហន្តរាយ។

**មាត្រា ៤**
**សិទ្ធិអំណាច**

៤.១ **អេឌីភីស៊ី** មានបុគ្គលភាពគតិយុត្តអន្តរជាតិ និងបុគ្គលភាពគតិយុត្តក្រោមច្បាប់របស់រដ្ឋសមាជិក។

៤.២ ដើម្បីឱ្យគោលដៅខាងលើសម្រេចបាន **អេឌីភីស៊ី** ត្រូវមានអំណាចដូចខាងក្រោម៖

(ក) ទទួលបានកាន់កាប់ ឬប្រគល់ឲ្យដោយស្របច្បាប់ពីអាជ្ញាធររដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្ម សមាគមន៍ រូបវន្តបុគ្គល មូលនិធិ ឬអង្គភាពដទៃទៀត អាចជាស្ថាប័នអន្តរជាតិ ថ្នាក់តំបន់ ឬថ្នាក់ជាតិ នូវកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ សិទ្ធិ សម្បទាន ឬសិទ្ធិប្រហាក់ប្រហែលគ្នា និងជំនួយហិរញ្ញវត្ថុ ឬផ្សេងពីនេះដែលមានប្រយោជន៍និងចាំបាច់ សម្រាប់សម្រេចគោលដៅរបស់ **អេឌីភីស៊ី** ។

(ខ) ទទួលបាន កាន់កាប់ ឬប្រគល់ឲ្យ ដោយស្របច្បាប់ពីអាជ្ញាធររដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្ម សមាគមន៍ រូបវន្តបុគ្គល មូលនិធិ ឬអង្គភាពដទៃទៀត អាចជាស្ថាប័នអន្តរជាតិ ថ្នាក់តំបន់ ឬថ្នាក់ជាតិ តាមរយៈជំនួយ ការផ្តល់វិភាគទាន ការផ្លាស់ប្តូរ សម្ភារៈអំណោយជាកេរ្តិ៍បរតក ការជាវ ឬជាកិច្ចសន្យា ថ្លៃឈ្នួលសម្រាប់ផ្តល់សេវាកម្មផ្តាច់មុខ ឬទទួលគ្រប់គ្រង ការផ្តល់វិភាគទានជាទ្រព្យសម្បត្តិ វត្ថុ បុគ្គលិក ឬរួមចំណុះរាប់បញ្ចូលនូវមូលនិធិ និងវត្ថុ ឬសម្ភារៈមានតម្លៃ ដែលអាចជាប្រយោជន៍ ឬចាំបាច់ ក្នុងការសម្រេចតាមចក្ខុវិស័យ និងគោលដៅរបស់ **អេឌីភីស៊ី** និង ដើម្បីគ្រប់គ្រងប្រតិបត្តិការដឹកនាំ ប្រើប្រាស់ លក់ដូរ ផ្ទេរ ឬចាត់ចែងនូវទ្រព្យសម្បត្តិទាំងនោះ។

(គ) ធ្វើកិច្ចព្រមព្រៀង ឬកិច្ចសន្យា។

(ឃ) ប្រើប្រាស់បុគ្គលិកដោយយោងទៅតាមវិធាន និងបទប្បញ្ញាត្តិរបស់ខ្លួនដោយគ្មានការរិតត្បិតផ្អែកតាមសញ្ជាតិ យេនឌ័រ ឬសាសនាឡើយ។

(ង) ផ្តួចផ្តើម និងការពារក្តីក្នុងដំណើរការតាមផ្លូវច្បាប់។

(ច) ប្រតិបត្តិគ្រប់សកម្មភាព និងតួនាទី ដែលចាំបាច់ បន្ទាន់ សមស្រប ឬត្រឹមត្រូវសម្រាប់ការពង្រឹងបន្ថែម ការសម្រេចបាន ឬឈានទៅសម្រេចបាននូវគ្រប់គោលដៅ ឬសកម្មភាពណាមួយ ឬទាំងអស់ ដែលបានចែងក្នុងអត្ថបទនេះ ឬអាចលេចចេញជារូបរាងឡើងនៅពេលណាមួយដែលអាចមានប្រយោជន៍ ឬចាំបាច់ដល់គោលដៅ និងសកម្មភាពរបស់ **អេឌីភីស៊ី** ។

៤.៣ មិនមានចំណែកនៃចំណូលណាមួយរបស់ **អេឌីភីស៊ី** ត្រូវបានយកទៅដាក់ធានា ឬប្រគល់ឱ្យអ្នកគ្រប់គ្រង ឬមន្ត្រី ឬបុគ្គលឯកជនណាមួយឡើយ លើកលែងតែក្នុងករណីដែល **អេឌីភីស៊ី**

អនុញ្ញាត ឬផ្តល់អំណាចក្នុងការផ្តល់នូវប្រាក់សំណងសមស្របសម្រាប់សេវាកម្មដែលបានទទួល និងធ្វើការទូទាត់ ព្រមទាំងការបែងចែងក្នុងការជួយជ្រោមជ្រែងដល់គោលដៅ ដែលមានចែងក្នុងមាត្រា៣ នៃធម្មនុញ្ញនេះ។

## មាត្រា ៥
## ស្ថាប័ន

៥. ស្ថាប័នរបស់ **អេឌីភីស៊ី** រួមមានៈ

(ក) ក្រុមប្រឹក្សាភិបាល

(ខ) ក្រុមប្រឹក្សាផ្តល់យោបល់

(គ) គណៈកម្មាធិការពិគ្រោះយោបល់ថ្នាក់តំបន់

(ឃ) គណៈកម្មាធិការប្រតិបត្តិ

## មាត្រា ៦
## ក្រុមប្រឹក្សាភិបាល

៦.១ បន្ទាប់ពីចុះហត្ថលេខាលើធម្មនុញ្ញនេះ សមាជិកស្ថាបនិកនីមួយៗ នឹងធ្វើការតែងតាំងសមាជិកម្នាក់ នៃក្រុមប្រឹក្សាភិបាល។ សមាជិកទាំងនេះ នឹងអញ្ជើញបុគ្គលបន្ថែមទៀតមកធ្វើការនៅក្នុងក្រុមប្រឹក្សាភិបាលនេះ។ ក្រុមប្រឹក្សាភិបាលមានសមាជិកយ៉ាងតិច ៥រូប និងមិនលើសពី ២៣រូបឡើយ។ សមាសភាពរបស់ក្រុមប្រឹក្សាភិបាល មានលក្ខណៈជាអន្តរជាតិ ដោយឆ្លុះបញ្ចាំង ពីចរិតលក្ខណៈនៃគោលដៅរបស់ **អេឌីភីស៊ី** ។ ទាំងប្រធាន និងអនុប្រធាន ត្រូវមានទីលំនៅក្នុងប្រទេសថៃ។ ប្រធាន និងអនុប្រធាន ត្រូវតែមានសញ្ជាតិខុសគ្នា។ សមាជិកទាំងឡាយអាចមានសញ្ជាតិណាមួយក៏បាន លើកលែងតែសមាជិកមានសញ្ជាតិដូចគ្នាមិនលើសពីមួយភាគបួននៃសមាជិកទាំងអស់។

៦.២ ក្រុមប្រឹក្សាភិបាលនឹងធ្វើការជួបប្រជុំយ៉ាងតិចមួយដងក្នុងមួយឆ្នាំ នៅក្នុងការិយាល័យកណ្តាលរបស់ **អេឌីភីស៊ី** ឬនៅកន្លែងណាមួយដែលក្រុមប្រឹក្សាភិបាលបានសម្រេច។

៦.៣ ក្រុមប្រឹក្សាភិបាល មានអំណាច និង តួនាទីដូចខាងក្រោមៈ

(ក) រៀបចំគោលនយោបាយរបស់ **អេឌីភីស៊ី** និងត្រួតពិនិត្យលើប្រតិបត្តិការ គ្រប់គ្រង ការចាត់ចែង ដោយផ្អែកតាមគោលនយោបាយរបស់ខ្លួន។

(ខ) ទទួលជំនួយហិរញ្ញវត្ថុឬជំនួយតាមទម្រង់ផ្សេងទៀតពីបណ្តាប្រទេសផ្តល់ជំនួយ ស្ថាប័ន និងភ្នាក់ងារដទៃទៀត ដែលជាតម្រូវការសម្រាប់ប្រតិបត្តិការរបស់ **អេឌីភីស៊ី**។

(គ) ឯកភាពលើរបាយការណ៍សវនកម្ម របាយការណ៍ហិរញ្ញវត្ថុ និងផែនការប្រចាំឆ្នាំ និងធានានូវការចំណាយប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព សុចរិតភាពនៃថវិការបស់ **អេឌីភីស៊ី** ។

(ឃ) បង្កើតអនុមជ្ឈមណ្ឌល ដែលមានទីតាំងនៅក្នុងប្រទេសនៃតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

(ង) អនុម័តលក្ខន្តិកៈរបស់ខ្លួនស្របទៅតាមធម្មនុញ្ញនេះ។

(ច) ឯកភាពលើគោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុ និងជ្រើសរើស សវនករពីខាងក្រៅ។

(ឆ) ឯកភាពលើក្របខ័ណ្ឌដឹកនាំទូលំទូលាយ របស់ **អេឌីភីស៊ី**។

(ជ) ឯកភាពលើគោលនយោបាយបុគ្គលិក រួមមានកម្រិតនៃប្រាក់បៀវត្ស និងផលប្រយោជន៍ផ្សេងៗទៀត។

(ឈ) តែងតាំង ឬបណ្តេញចេញនាយកប្រតិបត្តិ។

(ញ) អញ្ជើញបុគ្គលដែលមានលក្ខណៈសម្បត្តិមកធ្វើជាសមាជិក ឬជាទីប្រឹក្សារបស់ក្រុមប្រឹក្សាភិបាល។

(ដ) រក្សាទំនាក់ទំនងជាមួយស្ថាប័នដទៃទៀត ដែលយល់ថាសមស្រប។

(ឋ) អនុវត្តតួនាទីសមស្របដទៃទៀត និង ធ្វើសកម្មភាពណាមួយដែលអាចនាំឱ្យសម្រេចគោលបំណងរបស់ **អេឌីភីស៊ី**។

៦.៤ ក្រុមប្រឹក្សាភិបាលអាចនឹងធ្វើការផ្ទេរអំណាចណាមួយទៅដល់គណៈកម្មាធិការប្រតិបត្តិ។

៦.៥ ប្រធានក្រុមប្រឹក្សាភិបាលមានអំណាច និងការទទួលខុសត្រូវដូចខាងក្រោម៖

(ក) ធ្វើជាប្រធាននៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

(ខ) ធ្វើការកោះប្រជុំក្រុមប្រឹក្សាភិបាល។

(គ) ចុះហត្ថលេខាលើបទប្បញ្ញត្តិ សំណុំឯកសារ និងលិខិតទាំងអស់ដែលជារបស់ **អេឌីភីស៊ី**។ ឯកសារទាំងនេះ នឹងក្លាយជាផ្លូវការ លុះត្រាមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬសមាជិកទទួលបានការផ្ទេរសិទ្ធិ។

(ឃ) អំណាច និងការទទួលខុសត្រូវដទៃទៀត ផ្អែកទៅតាមសេចក្តីសម្រេចដោយមតិភាគច្រើននៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនិងបទប្បញ្ញត្តិរបស់ **អេឌីភីស៊ី**។

៦.៦ នាយកប្រតិបត្តិរបស់ **អេឌីភីស៊ី** នឹងក្លាយជាប្រធានប្រតិបត្តិរបស់ **អេឌីភីស៊ី** និងជាលេខាធិការរបស់ក្រុមប្រឹក្សាភិបាល។ គាត់ត្រូវតែជាសមាជិកតាមផ្លូវការនៅក្នុងក្រុមប្រឹក្សាភិបាល។ នាយកប្រតិបត្តិទទួលខុសត្រូវចំពោះក្រុមប្រឹក្សាភិបាលលើការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ **អេឌីភីស៊ី** និងលើការធានាថាគោលបំណងរបស់ខ្លួនត្រូវបានរៀបចំដោយសមស្រប ហើយកម្មវិធី ទាំងឡាយត្រូវបានអនុវត្តន៍។

## មាត្រា ៧
## ក្រុមប្រឹក្សាផ្តល់យោបល់

៧.១ ក្រុមប្រឹក្សាផ្តល់យោបល់ផ្តល់នូវបណ្តាញការងារមិនផ្លូវការមួយរបស់បុគ្គលទាំងឡាយដែលប្តេជ្ញាចិត្តចំពោះការកាត់បន្ថយគ្រោះមហន្តរាយនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដើម្បីចង្អុលបង្ហាញ **អេឌីភីស៊ី** ឱ្យទទួលបានជោគជ័យនូវចក្ខុវិស័យ និងគោលដៅរបស់ខ្លួន។

៧.២ សមាជិកក្រុមប្រឹក្សាផ្តល់យោបល់ គឺជាបុគ្គលមានសញ្ជាតិណាមួយដែលរស់នៅទីកន្លែងណាមួយនៅក្នុងពិភពលោក ដែលមានចំណាប់អារម្មណ៍លើផលប្រយោជន៍នៃប្រទេសនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ងាយទទួលរងគ្រោះដោយគ្រោះមហន្តរាយ និងជាបុគ្គលដែលគាំទ្រនូវចក្ខុវិស័យ គោលដៅ និងការរីកចម្រើនរបស់ **អេឌីភីស៊ី**។ បុគ្គលទាំងនេះអាចជាបុគ្គលឆ្នើមដែលទទួលស្គាល់ដោយ **អេឌីភីស៊ី** និងជាសមាជិករបស់រដ្ឋាភិបាលទាំងឡាយ ព្រមទាំងអង្គការសំខាន់ៗ ដែលមានទំនាក់ទំនងការងារជាមួយ **អេឌីភីស៊ី** ។

៧.៣ តួនាទីរបស់សមាជិកក្រុមប្រឹក្សាផ្តល់យោបល់៖

(ក) កំណត់នូវតម្រូវការទាក់ទងទៅនឹងគ្រោះមហន្តរាយរបស់បណ្តាប្រទេស នៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក និងធ្វើការភ្ជាប់ទំនាក់ទំនងជាមួយនឹង **អេឌីភីស៊ី**។

(ខ) ជួយក្នុងការកំណត់កាលានុវត្តភាពសម្រាប់ **អេឌីភីស៊ី** ដើម្បីជួយបំពេញសេចក្តីត្រូវការទាក់ទងនឹងគ្រោះមហន្តរាយនៃបណ្តាប្រទេសនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក និងផ្តល់ការណែនាំដល់ **អេឌីភីស៊ី** អំពីវិធីដែលអាចសម្រេចចក្ខុវិស័យ និង គោលដៅរបស់ខ្លួន។

(គ) ធ្វើការត្រួតពិនិត្យឡើងវិញ ឬផ្តល់យោបល់លើផ្នែកណាមួយពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្ររបស់ **អេឌីភីស៊ី** កម្មវិធីការងារ ឬសកម្មភាពការងារជាក់លាក់ដទៃទៀត តាមការអញ្ជើញរបស់នាយកប្រតិបត្តិ។

៧.៤ សមាជិកភាពត្រូវទទួលបានតាមរយៈការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃ **អេឌីភីស៊ី** ដោយមានការពិគ្រោះយោបល់ជាមួយនាយកប្រតិបត្តិ។ សមាជិកភាពមានរយៈពេល ៣ឆ្នាំ និងអាចបន្តជាថ្មី តាមឆន្ទានុសិទ្ធិរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃ **អេឌីភីស៊ី**។

## មាត្រា ៨
## គណៈកម្មាធិការពិគ្រោះយោបល់ថ្នាក់តំបន់

៨.១ គណៈកម្មាធិការពិគ្រោះយោបល់ថ្នាក់តំបន់ ផ្តល់នូវយន្តការមិនចងជាកាតព្វកិច្ចដូចជា៖

(ក) រៀបចំសកម្មភាពជាយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីហ្វិក។

(ខ) លើកកម្ពស់កម្មវិធីសហប្រតិបត្តិការ ថ្នាក់តំបន់ និងអនុតំបន់។

(គ) ផ្តល់ការណែនាំដល់ **អេឌីភីស៊ី** អំពីយុទ្ធសាស្ត្រ និងការងារនាពេលអនាគត។

៨.២ សមាជិកគណៈកម្មាធិការពិគ្រោះយោបល់ថ្នាក់តំបន់នៃ **អេឌីភីស៊ី** ត្រូវជ្រើសចេញពីសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ដែលកំពុងកាន់តួនាទីសំខាន់ៗនៅក្នុងជួររដ្ឋាភិបាល នៃស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិនៃបណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

៨.៣ សមាជិកភាពត្រូវទទួលបាន តាមរយៈការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃ **អេឌីភីស៊ី** ដោយមានការពិគ្រោះយោបល់ជាមួយនាយកប្រតិបត្តិ។ សមាជិកភាពនឹងមានរយៈពេល ៣ឆ្នាំ និងអាចបន្តជាថ្មី តាមឆន្ទានុសិទ្ធិរបស់ប្រធានក្រុមប្រឹក្សាភិបាល នៃ **អេឌីភីស៊ី**។

## មាត្រា ៩
## គណៈកម្មាធិការប្រតិបត្តិ

៩.១ គណៈកម្មាធិការប្រតិបត្តិ ត្រូវបានតែងតាំងឡើងដោយក្រុមប្រឹក្សាភិបាល។ នាយកប្រតិបត្តិរបស់ **អេឌីភីស៊ី** នឹងធ្វើជាប្រធានគណៈកម្មាធិការប្រតិបត្តិ ហើយអនុប្រធានប្រតិបត្តិនៃ **អេឌីភីស៊ី** គឺជាសមាជិកតាមផ្លូវការ។ សមាជិកគណៈកម្មាធិការប្រតិបត្តិដទៃទៀតអាចនឹងត្រូវបានតែងតាំងតាមឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាភិបាលដែលអាចផ្ទេរសិទ្ធិទៅដល់នាយកប្រតិបត្តិ។

៩.២ សមាជិកគណៈកម្មាធិការប្រតិបត្តិអាចមានសញ្ជាតិណាមួយក៏បាន។

៩.៣ គណៈកម្មាធិការប្រតិបត្តិ នឹងអនុវត្តរាល់គោលនយោបាយ ដែលកំណត់ឡើងដោយក្រុមប្រឹក្សាភិបាលអនុវត្តតាមគោលការណ៍ណែនាំ ដែលបានដាក់ចុះដោយក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការគ្រប់គ្រង អេឌីភីស៊ី និងអនុវត្តនូវរាល់សេចក្តីណែនាំរបស់ក្រុមប្រឹក្សាភិបាល។ ជាពិសេស គណៈកម្មាធិការប្រតិបត្តិស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលត្រូវៈ

(ក) រៀបចំផែនការថវិកា និងការងារប្រចាំឆ្នាំ ដើម្បីដំណើរការ **អេឌីភីស៊ី** និងត្រួតពិនិត្យជាបន្តនូវផែនការទាំងនោះ។

(ខ) ពិនិត្យលើសកម្មភាពទាំងឡាយរបស់ **អេឌីភីស៊ី** ហើយត្រូវធានាការរៀបចំកម្មវិធី និងការអនុវត្តសកម្មភាពទាំងនោះឲ្យមានប្រសិទ្ធភាព។

(គ) ជ្រើសរើសបុគ្គលិក និងផ្តល់នូវភាពជាអ្នកដឹកនាំ។

(ឃ) ផ្តល់យោបល់ និងជម្រាបជូនប្រធានក្រុមប្រឹក្សាភិបាលឲ្យបានទៀងទាត់រាល់បញ្ហាដែលកើតឡើងទាក់ទងនឹង **អេឌីភីស៊ី** ។

(ង) អនុវត្តន៍តួនាទីផ្សេងទៀតដែលប្រគល់ឲ្យដោយក្រុមប្រឹក្សាភិបាល។

## មាត្រា ១០
## បុគ្គលិក

១០.១ បុគ្គលិករបស់**អេឌីភីស៊ី** ត្រូវបានតែងតាំងដោយនាយកប្រតិបត្តិក្នុងក្របខណ្ឌឯកភាពដោយក្រុមប្រឹក្សាភិបាល។

១០.២ ការពិចារណាដ៏ហ្មត់ចត់នៅក្នុងការប្រើប្រាស់បុគ្គលិក ឬការកំណត់លក្ខខណ្ឌនៃសេវាកម្មគឺត្រូវការជាចាំបាច់ ដើម្បីធានានូវគុណភាពខ្ពស់ ប្រសិទ្ធផល សមត្ថភាព និងសុចរិតភាព។ បុគ្គលិកអាចមានសញ្ជាតិណាមួយក៏បានដោយពិចារណានូវការរក្សាតុល្យភាពដ៏សមស្របនឹងប្រជាពលរដ្ឋថៃ និងបណ្តាប្រទេសដែល **អេឌីភីស៊ី** ធ្វើប្រតិបត្តិការ។

១០.៣ កម្រិតនៃប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗនឹងត្រូវបានកំណត់នៅក្នុងវិធានស្ដីពីបុគ្គលិកដែលឯកភាពដោយក្រុមប្រឹក្សាភិបាល។

**មាត្រា ១១**
**បទប្បញ្ញត្តិស្ដីពីហិរញ្ញវត្ថុ**

១១.១ **អេឌីភីស៊ី** អាចទទួលបាននូវមូលនិធិ ឬទ្រព្យសកម្មតាមមធ្យោបាយដូចខាងក្រោម៖

(ក) សាច់ប្រាក់/មូលនិធិ ឬទ្រព្យសម្បត្តិ ដែលបរិច្ចាគដោយរូបវន្តបុគ្គល ឬនីតិបុគ្គល សម្រាប់ហេតុផលការស្រឡាញ់រាប់អានមនុស្សជាតិ។

(ខ) អំណោយសម្រាប់អនុវត្តកម្មវិធី។

(គ) អំណោយដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់ **អេឌីភីស៊ី**។

(ឃ) ចំណូលទទួលបានតាមរយៈសកម្មភាពផ្សេងៗរបស់ **អេឌីភីស៊ី**។

(ង) ការប្រាក់ទទួលបានពីទ្រព្យសកម្មរបស់ **អេឌីភីស៊ី**។

(ច) វិភាគទានស្ម័គ្រចិត្តដោយអង្គការ និងបុគ្គលផ្សេងៗ ដែលចាប់អារម្មណ៍ក្នុងការជួយជ្រោមជ្រែងដល់ការសម្រេចគោលដៅរបស់ **អេឌីភីស៊ី**។

(ឆ) សាច់ប្រាក់ ឬទ្រព្យសម្បត្តិដែលបានផ្ដល់ឱ្យ **អេឌីភីស៊ី** តាមរយៈសំបុត្របណ្ដាំ ឬលិខិតបណ្ដាំមរតក ស្របច្បាប់ផ្សេងៗទៀតដោយគ្មានលក្ខខណ្ឌ ឬការសន្យាដល់ **អេឌីភីស៊ី** ឲ្យទទួលខុសត្រូវលើបំណុល ឬកាតព្វកិច្ចផ្លូវច្បាប់ផ្សេងទៀត។

(ជ) មធ្យោបាយស្របច្បាប់ដទៃទៀតដែលស្របទៅនឹងគោលបំណង **អេឌីភីស៊ី**។

១១.២ ក្រុមប្រឹក្សាភិបាលនឹងធ្វើការសម្រេចចិត្តអំពីកាលបរិច្ឆេទនៃការចាប់ផ្ដើមហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **អេឌីភីស៊ី**។

១១.៣ ប្រតិបត្តិការហិរញ្ញវត្ថុរបស់ **អេឌីភីស៊ី** ត្រូវបានគ្រប់គ្រងតាមស្តង់ដារហិរញ្ញវត្ថុដែលអាចទទួលយកបានជាលក្ខណៈអន្តរជាតិ។

១១.៤ ក្រុមប្រឹក្សាភិបាលនឹងបង្កើតនូវគោលនយោបាយ នីតិវិធីហិរញ្ញវត្ថុ គណនេយ្យ និងការគ្រប់គ្រងទ្រព្យសកម្មរបស់ **អេឌីភីស៊ី** ព្រមទាំងកំណត់ កម្រិតអនុញ្ញាតសម្រាប់ការឯកភាពផ្នែកហិរញ្ញវត្ថុ។

១១.៥ សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាលមានសិទ្ធិពិនិត្យលើបញ្ជីគណនេយ្យរបស់ **អេឌីភីស៊ី**។ ក្រុមប្រឹក្សាភិបាល អាចកំណត់កម្រិតដោយសមហេតុផលនូវពេលវេលា និងវិធីសាស្ត្រដើម្បីឲ្យសមាជិករបស់ខ្លួនអាចពិនិត្យមើលបញ្ជីគណនេយ្យបាន ។

១១.៦ សវនកម្មហិរញ្ញវត្ថុពេញលេញមួយលើប្រតិបត្តិការរបស់ **អេឌីភីស៊ី** នឹងត្រូវបានធ្វើឡើងប្រចាំឆ្នាំដោយក្រុមហ៊ុនសវនកម្មឯករាជ្យមួយតែងតាំងដោយក្រុមប្រឹក្សាភិបាល ផ្អែកតាមអនុសាសន៍របស់នាយកប្រតិបត្តិ។ របាយការណ៍សវនកម្មត្រូវដាក់ជូនទៅក្រុមប្រឹក្សាភិបាលដោយនាយកប្រតិបត្តិដើម្បីធ្វើការពិចារណា និងឯកភាព។

## មាត្រា ១២
## បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១២ . អេឌីភីស៊ី ត្រូវអនុវត្តដោយបេកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការទទួលបានពីរដ្ឋាភិបាលថៃ និងប្រទេសជាម្ចាស់ផ្ទះដទៃទៀតដែលខ្លួនធ្វើការ នូវកិច្ចព្រមព្រៀងផ្សេងៗដែលចាំបាច់ក្នុងគោលបំណងដើម្បីឲ្យ **អេឌីភីស៊ី** និងមន្ត្រីរបស់ខ្លួនទទួលបាននូវមធ្យោបាយ បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិ ការរួចផុតពីទម្រង់ហាមឃាត់ណាមួយដូចជា អន្តោប្រវេសន៍ ការបង់ពន្ធលើប្រាក់ចំណូល កាតព្វកិច្ចគយ សម្រាប់ដំណើរការការងាររបស់ខ្លួន។

## មាត្រា ១៣
## ការធ្វើវិសោធនកម្ម

១៣. ធម្មនុញ្ញនេះអាចធ្វើវិសោធនកម្មបានដោយក្រុមប្រឹក្សាភិបាលតាមសំលេងភាគច្រើន បីភាគបួននៃសមាជិកក្រុមប្រឹក្សាភិបាលដែលមានវត្តមាននៅក្នុងកិច្ចប្រជុំស្របច្បាប់ និងតាមរយៈការបោះឆ្នោតដោយចំហ លុះត្រាតែមានការជូនដំណឹងស្តីពី វិសោធនកម្មនោះដោយអមនូវអត្ថបទពេញលេញផងត្រូវបានចែកជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ យ៉ាងតិចប្រាំបីសប្តាហ៍មុនកិច្ចប្រជុំ ឬលុះត្រាតែការជូនដំណឹងត្រូវបានបដិសេធដោយសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

## មាត្រា ១៤
## ការរំលាយ

១៤.១ យោងតាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល **អេឌីភីស៊ី** អាចត្រូវបារំលាយដោយ សំលេងភាគច្រើន បីភាគបួន នៃសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមាន នៅក្នុងកិប្រជុំដោយស្របច្បាប់ និងតាមរយៈការបោះឆ្នោតជាចំហ។ ការរំលាយនឹងចូលជាធរមាន បន្ទាប់ពីមានការឯកភាពរបស់ភាគីហត្ថលេខី។ នីតិវិធីដូចគ្នាសម្រាប់ការជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាភិបាល ដូចបានបញ្ជាក់នៅក្នុងមាត្រា១៣ នឹងយកមកអនុវត្ត។

១៤.២ ក្នុងករណីមានការរំលាយ ទ្រព្យសម្បត្តិរបស់ **អេឌីភីស៊ី** ដែលស្ថិតនៅក្នុងប្រទេសថៃ នឹងត្រូវបានបញ្ជូនដោយក្រុមប្រឹក្សាភិបាលឱ្យទៅអង្គការមួយ ជ្រើសរើសដោយក្រុមប្រឹក្សាភិបាលដែលមានគោលបំណងស្រដៀងគ្នាទៅនឹង **អេឌីភីស៊ី**។ ទ្រព្យសម្បត្តិរបស់ **អេឌីភីស៊ី** ដែលស្ថិតនៅក្នុងប្រទេសដទៃទៀតក្នុងតំបន់អាស៊ី និង ប៉ាស៊ីហ្វិក នឹងត្រូវបានបញ្ជូនដោយក្រុមប្រឹក្សាភិបាលក្នុងគោលដៅប្រើប្រាស់សម្រាប់គោលបំណងប្រហាក់ប្រហែលគ្នា នៅក្នុងប្រទេសនោះ ឬអង្គការនានានៅក្នុងប្រទេសទាំងនោះដែលមានគោលបំណងដូចគ្នាទៅនឹង **អេឌីភីស៊ី**។

## មាត្រា ១៥
## ការចូលជាធរមាន

ធម្មនុញ្ញនេះ នឹងចូលជាធរមានបន្ទាប់ពីការផ្តល់សច្ចាប័នដោយសមាជិកស្ថាបនិកទាំងអស់។

ច្បាប់ដើមនៃធម្មនុញ្ញនឹងត្រូវតម្កល់ទុកជាមួយនឹងរាជរដ្ឋាភិបាលថៃ ដែលនឹងផ្ញើសំណៅចំលងបញ្ជាក់មួយច្បាប់ទៅកាន់សមាជិកស្ថាបនិក។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលនីមួយៗរបស់ខ្លួន បានចុះហត្ថលេខាលើធម្មនុញ្ញនេះ។

ធ្វើនៅទីក្រុងបាំងកក ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ -ច្បាប់ដើមជាភាសាអង់គ្លេស

ជំនួសមុខឱ្យរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស
ហត្ថលេខា

(Shahed Akhtar)
ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ប្រចាំនៅព្រះរាជាណាចក្រថៃ

ជំនួសមុខឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
ហត្ថលេខា

(Ung Sean)
ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅព្រះរាជាណាចក្រថៃ

ជំនួសមុខឱ្យរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន
ហត្ថលេខា

(Zhnag Huhuan)
ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រថៃ

ជំនួសមុខឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រនេប៉ាល់
ហត្ថលេខា

(Yadav Khanal)
ឯកអគ្គរាជទូតព្រះរាជាណាចក្រនេប៉ាល់ ប្រចាំនៅព្រះរាជាណាចក្រថៃ

# ASIAN DISASTER PREPAREDNESS CENTER

## CHARTER

สำเนาถูกต้อง
CERTIFIED TRUE COPY
Dr. Suvit Yodmani
Executive Director
Asian Disaster Preparedness Center

# CHARTER

# OF THE

# ASIAN DISASTER PREPAREDNESS CENTER

## Article 1

## ESTABLISHMENT AND ORGANIZATION

1.1 Within this Charter, the Founders establish The Asian Disaster Preparedness Center (hereinafter called the "ADPC"). The ADPC shall operate as a non-profit, autonomous, regional organization, international in status and non-political in management, staffing and operations. The ADPC shall be organized for scientific, educational, developmental and humanitarian purposes.

1.2 The seat of the ADPC shall be in Thailand.

1.3 The official language for the purpose of communication and business records of the ADPC shall be English; however, all languages relevant to Asian and Pacific countries shall be used, as practicable, for purposes of technical training, instruction and information dissemination to participants or the public.

## Article 2

## MEMBERSHIP

2.1 Membership of ADPC is open to member states of the United Nations.

2.2 The signatories to this Charter are Founding Members of the ADPC.

2.3 The Members shall not be obliged to pay membership fees, but may make voluntary contributions to the funds of the ADPC.

## Article 3

## VISION AND OBJECTIVES

3.1 The vision of the ADPC is safer communities and sustainable development through disaster reduction.

3.2 The objectives of the ADPC are to reduce the impact of disasters on communities and countries in Asia and the Pacific. It shall pursue its objectives for the greatest social benefit with due regard to cross-cultural perspectives through the following means:

(a) to assist Asian and Pacific countries and communities in developing their policies and capacities to mitigate the impact of disasters by organizing, providing, facilitating and otherwise supporting training, information management, research, project or programme management and technical assistance;

(b) to promote disaster awareness for the protection of life, property and the environment;

(c) to promote networking and collaboration between national and regional disaster management organizations;

(d) to promote the exchange of experiences and lessons learned in disasters between countries, communities and organizations;

(e) to collaborate with all relevant sectors in strengthening community capacities to participate in developmental activities for disaster preparedness;

(f) to promote and implement individually, or in partnerships with other national and international organizations, programs or other activities for public benefit;

(g) as far as is practicable, to seek to integrate local wisdom and customs with modern knowledge and institutional practices towards the achievement of its objectives;

(h) to serve as a bridge between government organizations and the institutions of civil society such as local communities and non-governmental organizations;

(i) to serve as a forum for the development and strengthening of cooperation among individuals and organizations such as governments, non-governmental organizations, private companies, local communities and their leaders and functionaries, academicians, journalists, researchers, planners, policy makers and implementers at all levels, whose work is consistent with the objectives of the ADPC;

(j) to achieve long-term financial sustainability.

3.3 In support of its objectives the ADPC shall undertake and facilitate relevant research, technical assistance, the exchange of information, workshops, conferences, training activities, seminars, linkages with appropriate individuals and institutions, fund-raising for and promotion of its services, and any other activity that may derive from or enhance the role of the ADPC as a regional center for the promotion of disaster reduction.

## Article 4

## POWERS

4.1 The ADPC shall possess international personality and juridical personality under the law of members.

4.2 In furtherance of the aforesaid objectives, the ADPC shall have the following powers:

(a) to receive, acquire or otherwise lawfully obtain from any governmental authority or from any corporation, company, association, person, firm, foundation or other entity whether international, regional or national, such charters, licenses, rights, concessions, or similar rights, and assistance – financial or otherwise – as are conducive to and necessary for the attainment of the objectives of the ADPC;

(b) to receive, acquire or otherwise lawfully obtain from any governmental authority or from any corporation, company, association, person, firm, foundation or other entity, whether international, regional or national, by donation, grant, exchange, device, bequest, purchase or lease, fees for provision of services, whether absolutely or in trust, contributions consisting of such properties, real, personal, or mixed, including funds and valuable effects or items, as may be useful or necessary to pursue the vision and objectives of the ADPC and to hold, operate, administer, use, sell, convey or dispose of the said properties;

(c) to enter into agreements and contracts;

(d) to employ persons according to its own rules and regulations without restriction as to nationality, gender or religion;

(e) to institute and defend legal proceedings;

(f) to perform all acts and functions which may be necessary, expedient, suitable, or proper for the furtherance, accomplishment or attainment of any or all of the purposes and activities herein stated, or which may appear, at any time, conducive to or necessary and useful for the objectives and activities of the ADPC.

4.3 No part of the earnings of the ADPC shall inure or be distributable to its trustees, officers, or other private persons, except that the ADPC shall be authorized and empowered to pay reasonable compensation for services rendered and to make payments and distributions in furtherance of the objectives set out in Article 3.

## Article 5

## ORGANS

5. The organs of the ADPC shall be:

(a) the Board of Trustees (the Board);

(b) the Advisory Council;

(c) the Regional Consultative Committee;

(d) the Executive Committee.

Article 6

THE BOARD

6.1 On signing this Charter each Founding Member shall appoint a member of the Board. These members shall then invite additional individuals to serve on the Board. The Board shall consist of not less than five and not more than twenty three individuals. The composition of the Board shall be international in character reflecting the nature of the ADPC's objectives. Either the Chairman or Vice-Chairman shall be resident in Thailand. The Chairman and Vice Chairman shall always be of different nationalities. Members may be of any nationality save that not more than one quarter may be of the same nationality.

6.2 The Board shall meet at least once a year in the principal office of the ADPC or at such places as the Board may determine.

6.3 The Board shall have the following powers and functions:

(a) to set policies of the ADPC and oversee its organization, management and operations according to those policies;

(b) to accept financial or other forms of aid from donor countries, institutions and agencies as may be required for the operation of the ADPC;

(c) to approve the yearly workplan, budget and auditor's report and to ensure the ADPC's cost-effectiveness, financial integrity and accountability;

(d) to establish sub-centers located in countries in Asia and the Pacific;

(e) to adopt its own Bye-Laws in line with this Charter;

(f) to approve financial policies and procedures and appoint external auditors;

(g) to approve the ADPC's broad organizational framework;

(h) to approve personnel policies, including scales of salaries and benefits;

(i) to appoint or dismiss the Executive Director;

(j) to invite suitable persons to be members of or advisors to the Board;

(k) to maintain affiliations with other institutions as deemed appropriate;

(l) to exercise any other powers and to do any acts conducive to the achievement of the objectives of the ADPC.

6.4 The Board may delegate any of its powers to the Executive Committee.

6.5 The Chairman of the Board shall have the following authority and responsibilities:

(a) chair meetings of the Board;

(b) convene meetings of the Board;

(c) sign ADPC's regulations, and all types of documents/letters, which are evidence of the ADPC. These documents will be official only with the signature of the Chairman of the Board, or designated Board members;

(d) other authority and responsibilities according to a majority resolution of a Board meeting and the ADPC's regulations.

6.6 The Executive Director of the ADPC shall be the Chief Executive of the ADPC and Secretary to the Board. He shall be an *ex-officio* member of the Board. The Executive Director is responsible to the Board for the operation and management of the ADPC and for ensuring that its objectives are properly developed and its programs are carried out.

## Article 7

## THE ADVISORY COUNCIL

7.1 The Advisory Council provides an informal network of individuals committed to disaster reduction in Asia and the Pacific in order to guide ADPC in the furtherance of its vision and objectives.

7.2 Advisory Council members are individuals of any nationality living anywhere in the world who have at heart the interests of disaster-prone countries in Asian and the Pacific and who wish to support ADPC's vision, objectives and institutional growth. They include eminent individuals known personally to ADPC and members of governments and key organizations associated with ADPC's work.

7.3 The role of the Advisory Council members is to:

(a) identify the disaster-related needs of countries in Asia and the Pacific and communicate them to ADPC;

(b) assist in identifying opportunities for ADPC to help meet the disaster-related needs of countries and communities in Asia and the Pacific, and to provide guidance to ADPC on how to achieve its vision and objectives;

(c) at the invitation of the Executive Director, to review or advise on relevant portions of the ADPC strategy, work program or other specific activities.

7.4 Membership is by invitation of the Chairman of the ADPC Board of Trustees in consultation with the Executive Director. Membership will be for a period of three years, renewable at the discretion of the Chairman of the ADPC Board of Trustees.

Article 8

THE REGIONAL CONSULTATIVE COMMITTEE

8.1 The ADPC Regional Consultative Committee provides an ongoing non-binding mechanism for:

(a) the development of action strategies for disaster reduction in Asia and the Pacific;

(b) promoting cooperative programs on a regional and sub-regional basis;

(c) providing guidance to ADPC on its future work and strategies.

8.2 The ADPC Regional Consultative Committee members are drawn from Board Members or Members of the Advisory Council who are occupying key government positions in the national disaster management systems of countries in Asia and the Pacific.

8.3 Membership is by invitation of the Chairman of the ADPC Board of Trustees in consultation with the Executive Director. Membership will be for a period of three years, renewable at the discretion of the Chairman of the ADPC Board of Trustees.

Article 9

THE EXECUTIVE COMMITTEE

9.1 The Executive Committee shall be appointed by the Board. The Executive Director of the ADPC shall be the Chairman of the Executive Committee and the Deputy Executive Director of the ADPC shall be an *ex-officio* member. Other Executive Committee members may be appointed at the discretion of the Board which may delegate this authority to the Executive Director.

9.2 Members of the Executive Committee may be of any nationality.

9.3 The Executive Committee shall implement the policies determined by the Board, follow the guidelines laid down by the Board for the administration of the ADPC and carry out all directions of the Board. Specifically, the Executive Committee, under the supervision of the Board, shall:

(a) develop yearly work plans and budgets for the operation of the ADPC and keep these plans under continuing review;

(b) supervise the activities of the ADPC and ensure effective programming and implementation of the activities;

(c) recruit the staff and provide leadership;

(d) keep the Chairman of the Board advised and informed of all matters of consequence relating to the ADPC;

(e) perform such other functions as may be delegated by the Board.

### Article 10

### STAFFING

10.1 The staff of the ADPC shall be appointed by the Executive Director within the framework approved by the Board.

10.2 The paramount consideration in the employment of staff and in the determination of the conditions of service shall be the necessity of securing the highest standards of quality, efficiency, competence and integrity. Staff may be of any nationality including an appropriate balance of nationals of Thailand and the countries in which ADPC operates.

10.3 Salary scales and other benefits shall be laid down in staff regulations approved by the Board.

## Article 11

## FINANCIAL PROVISIONS

11.1 The ADPC may acquire its funds or assets by the following means:

- (a) cash/funds or assets donated by individuals and/or juristic persons for philanthropic reasons;
- (b) grants for implementation of programs;
- (c) grants for meeting the objectives of the ADPC;
- (d) income generated by the activities of the ADPC;
- (e) interest from assets of the ADPC;
- (f) voluntary contributions, by organizations & persons interested in furtherance of the ADPC objectives;
- (g) cash or assets given to the APDC by any will or testament or other legal deeds without any condition or commitment to the ADPC being liable to debt or other legal obligations;
- (h) any other lawful means consistent with the objectives of the ADPC.

11.2 The Board shall decide on the date of the commencement of the financial year of the ADPC.

11.3 The financial operations of the ADPC shall be governed by internationally acceptable accounting standards.

11.4 The Board shall establish the policies and procedures for finance, accounting and managing the assets of the ADPC, and determine the authorized levels for financial approvals.

11.5 Each member of the Board of Trustees has the right to inspect the books and accounts of the ADPC. The Board may impose reasonable restrictions as to the time and manner in which the books and accounts may be inspected by its members.

11.6 A full financial audit of the operations of the ADPC shall be conducted on an annual basis by an independent auditing firm appointed by the Board upon the recommendation of the Executive Director. Such audit reports shall be submitted by the Executive Director to the Board for its consideration and approval.

Article 12

PRIVILEGES AND IMMUNITIES

12 The ADPC shall exercise the utmost diligence in obtaining from the Government of Thailand and any other host country in which it works, such agreements as are necessary for the purpose of obtaining for the ADPC, its officials, and facilities, privileges or immunities from any form of restrictions, such as immigration, income taxes and customs duties, as are required for their work.

Article 13

AMENDMENTS

13 This Charter may be amended by the Board by a three-fourths majority of the voting Members of the Board of Trustees present at a legally constituted meeting and by open voting, provided that notice of such proposed amendment, together with its full text, shall have been mailed to all Board Members at least eight weeks in advance of the meeting, or that such notice is waived by all the Board Members.

Article 14

DISSOLUTION

14.1 The ADPC may be dissolved, upon recommendation, by a three-fourths majority of the voting Members of the Board of Trustees present at a legally constituted meeting and by open voting. The

dissolution shall take effect upon agreement by the signatories. The same procedure for notice to the Board members, as stated in Article 13, shall apply.

14.2 In the event of a dissolution, the assets of the ADPC situated in Thailand shall be transferred by the Board of Trustees to an organization in Thailand selected by the Board of Trustees having purposes similar to that of ADPC. Assets of the ADPC situated in other countries in Asia and the Pacific shall be transferred by the Board of Trustees direction for use for similar purposes in the respective countries or to organizations in those countries having purposes similar to those of the ADPC.

Article 15

## ENTRY INTO FORCE

This Charter shall enter into force upon ratification by the Founding Members.

The original of this Charter shall be deposited with the Royal Thai Government, which shall send certified copies thereof to the Founding Members.

In witness whereof the undersigned, being duly authorized thereto by their respective Governments, have signed the present Charter.

Done at Bangkok in a single copy in the English language this 28th day of February 2005.

**For the Government of the People's Republic of Bangladesh**

(Shahed Akhtar) ad referendum
Ambassador of the People's Republic of Bangladesh
to Thailand

For the Government of the Kingdom of Cambodia

(Ung Sean)
Ambassador of the Kingdom of Cambodia
to Thailand

For the Government of the People's Republic of China

(Zhang Jiuhuan)
Ambassador of the People's Republic of China
to Thailand

For the Government of the Kingdom of Nepal

(Yadav Khanal)
Charge d' Affaires a.i.,
the Royal Nepalese Embassy to Thailand

For the Government of the Islamic Republic of Pakistan

(Mir Hussain Bakhsh Bangulzai)
Ambassador of the Islamic Republic of Pakistan
to Thailand

For the Government of the Republic of the Philippines

(Antonio Venus Rodriguez)
Ambassador of the Republic of the Philippines
to Thailand

For the Government of the Democratic Socialist Republic of Sri Lanka

(J.D.A. Wijewardena)
Ambassador of the Democratic Socialist Republic of Sri Lanka
to Thailand

For the Government of the Kingdom of Thailand

(Surakiart Sathirathai)
Minister of Foreign Affairs

For the Government of the Republic of India

(Mr. Vivek Katju)
Ambassador of the Republic of India